# វិធីសាស្ត្រនៃការបញ្ចេញយោបល់លើពង្រាងច្បាប់

## ក) សេចក្តីផ្តើម

ប្រសិនបើ គេយកចិត្តទុកដាក់លើការចូលរួមផ្នែកនយោបាយរបស់ប្រជាពលរដ្ឋនោះ សមាជិកនៃសង្គមស៊ីវិល (អង្គការមិនមែនរដ្ឋាភិបាល គណៈមេធាវី សហជីពកម្មករ ។ល។) នឹងមានឱកាសសម្តែងមតិរបស់ខ្លួនលើពង្រាងច្បាប់ផ្សេងៗបាន ។ នេះមានន័យថា ពួកគេត្រូវតែមានឱកាសៈ

- ដើម្បី **សម្តែងការព្រួយបារម្ភរបស់ពួកគេ** ទាក់ទងទៅនឹងមាត្រាផ្សេងៗនៃពង្រាងច្បាប់

និង

- ដើម្បី **ធ្វើសំណើសំរាប់កែប្រែ** (វិសោធនកម្ម) នូវមាត្រាពង្រាងច្បាប់ទាំងនេះ ។

ដើម្បីធ្វើដូច្នេះឱ្យបានសមស្រប និងប្រកបដោយប្រសិទ្ធភាពនោះ ពួកគេគួរពិនិត្យពង្រាងច្បាប់ទាំងនេះឱ្យបានល្អិតល្អន់ ។ បន្ទាប់មក ពួកគេត្រូវប្រមូល និងសរុបនូវការព្រួយបារម្ភរបស់ខ្លួនឱ្យបានខ្លី ហើយច្បាស់លាស់ទាក់ទងទៅនឹងមាត្រានីមួយៗ ។ ចុងក្រោយ ពួកគេត្រូវធ្វើសំណើសំរាប់វិសោធនកម្មក្នុង លក្ខណៈមួយដែលបង្ហាញច្បាស់ថា តើផ្នែកណាមួយនៃអត្ថបទព្រាងនេះត្រូវលុបចោល និងថាតើផ្នែកខ្លឹមសារណា ត្រូវជំនួស ឬត្រូវបន្ថែម ។

## ខ) ការពិនិត្យមាត្រានានានៃពង្រាងច្បាប់

### I) បញ្ជីត្រួតពិនិត្យត្រួសៗ (ការចាត់ថ្នាក់ទី ១):

នៅក្នុងជំហានទី១ គេអាចពិនិត្យត្រួសៗនូវពង្រាងច្បាប់ ដោយមើលមាត្រានីមួយៗនៃច្បាប់ និងដោយសួរសំនួរទាំងបី ដែលទាក់ទងទៅនឹងបញ្ហាសំខាន់ៗបីដែលអ្នកធ្វើច្បាប់តែងតែជួបប្រទះ:

**១) ពាក្យមិនច្បាស់លាស់:**
សំនួរដែលត្រូវសួរគឺ :

*"តើមានពាក្យមិនច្បាស់លាស់នៅក្នុងខ្លឹមសារនៃមាត្រានោះឬទេ?"*

(កំណត់សំគាល់: មុនពេលផ្តល់ចម្លើយ "បាទ/ចាស់" ចំពោះសំនួរនេះ គេត្រូវតែពិនិត្យមើលមាត្រាដូចខាងក្រោមនៃពង្រាងច្បាប់ជាមុនសិនថា តើមាត្រាទាំងនេះផ្តល់និយមន័យដល់ពាក្យនេះ ហើយឬនៅ ។)

សំនួរអំពីពាក្យមិនច្បាស់លាស់នេះ មានសារៈសំខាន់ណាស់ ទាក់ទងនឹងគោលការណ៍នៃការបែងចែកអំណាច ។ ប្រសិនបើពាក្យណាមួយមិនច្បាស់លាស់ អ្នកធ្វើច្បាប់មិនបានសម្តែងឆន្ទៈរបស់ប្រជាពលរដ្ឋច្បាស់លាស់គ្រប់គ្រាន់ឡើយ ។ ប្រការនេះ បើកឱកាសឱ្យមានការបកស្រាយច្បាប់បានដោយអំណាចនីតិប្រតិបត្តិ ឬតុលាការដែលមិនមានសិទ្ធិកំណត់ពីឆន្ទៈរបស់ប្រជាពលរដ្ឋ ។

**២) សិទ្ធិមនុស្ស:**

សំនួរដែលពាក់ព័ន្ធគឺ :

*"តើមាត្រានោះប៉ះពាល់ដល់សិទ្ធិមនុស្សឬទេ?*
*- ប្រសិនបើប៉ះពាល់ តើវាកំណត់ការដាក់កំហិតណាមួយមកលើសិទ្ធិនេះឬទេ?*
*- ប្រសិនបើកំណត់ តើគោលបំណងនៃការដាក់កំហិតនេះត្រូវបានអនុញ្ញាតដោយរដ្ឋធម្មនុញ្ញឬទេ?*
*- ប្រសិនបើអនុញ្ញាត តើការដាក់កំហិតនេះមានសមាមាត្រឬទេ?"*

សំនួរទាំងនេះមានសារៈសំខាន់ ពីព្រោះអ្នកធ្វើច្បាប់ត្រូវតែថ្លឹងថ្លែងសិទ្ធិរបស់បុគ្គលម្នាក់ៗ ហើយរកដំណោះស្រាយដ៏ត្រឹមត្រូវមួយ ដើម្បីការពារសិទ្ធិរបស់បុគ្គលម្នាក់ ប៉ុន្តែ មិនមែនដើម្បីដាក់កំហិតលើសិទ្ធិអ្នកដទៃខ្លាំងពេកឡើយ ។

**៣) ប្រតិភូកម្មនៃអំណាចធ្វើច្បាប់:**

ត្រង់ចំណុចនេះ សំនួរគឺ :

*" តើមាត្រានោះធ្វើប្រតិភូកម្មអំណាចធ្វើបទបញ្ញត្តិពី*
*នីតិបញ្ញត្តិដល់នីតិប្រតិបត្តិឬទេ?"*
*ប្រសិនបើដូច្នោះ តើច្បាប់ធ្វើប្រតិភូកម្មអំណាចច្រើនហួសហេតុ*
*ដល់នីតិប្រតិបត្តិឬទេ?"*

នៅពេលណាមួយដែលអត្ថបទច្បាប់និយាយអំពីពាក្យថា **"អនុក្រឹត្យ"** ឬ **"ប្រកាស"** ឬនិយាយអំពីលិខិតអនុញ្ញាតណាមួយដទៃទៀតដើម្បីឱ្យអំណាចនីតិប្រតិបត្តិបង្កើតលក្ខខណ្ឌបន្ថែមនោះ វាបង្ហាញឱ្យឃើញថាមាត្រានោះបញ្ចូលនូវ**ប្រតិភូកម្មអំណាចធ្វើច្បាប់ហើយ** ។

សំនួរអំពីប្រតិភូកម្មអំណាចបែបនេះ មានសារៈសំខាន់ណាស់ ទាក់ទងទៅនឹងគោលការណ៍នៃការបែង-ចែកអំណាច (មាត្រា៥១ III ២ និង IV CC) ។ ចំណុចនេះមិនមែនមានន័យថា ប្រតិភូកម្ម បំពានលើគោលការណ៍នោះទេ ។ ប៉ុន្តែ យើងត្រូវតែចាំឱ្យច្បាស់ថា មានតែបទបញ្ញត្តិនៃសេចក្តីលំអិតផ្នែករដ្ឋបាលតូចតាចប៉ុណ្ណោះ ដែលអាចទុកឱ្យនីតិប្រតិបត្តិដោះស្រាយបាន ចំណែកឯបញ្ហាចំបងៗត្រូវតែដោះស្រាយដោយច្បាប់ ។ បញ្ហាទាំងនេះ គឺជាបញ្ហាទាំងឡាយដែលមានចែងយ៉ាងច្បាស់លាស់នៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា (ឧទាហរណ៍: មាត្រា៤១ II CC: "របបសារពត៌មាន ត្រូវកំណត់ដោយច្បាប់" ឬ មាត្រា៤២ I ២ CC: "សិទ្ធិ (នៃការបង្កើតសមាគមដោយសេរី) ត្រូវកំណត់ដោយច្បាប់") ។

លើសពីនេះទៀត បញ្ហាទាំងអស់របស់សង្គម ត្រូវតែកំណត់ដោយច្បាប់មួយ ដែលប៉ះពាល់ដល់សិទ្ធិសេរីភាពរបស់មនុស្ស (ដោយការដាក់កំហិត ឬបំពានសិទ្ធិទាំងនេះ ជាឧទាហរណ៍ តម្លៃផ្លូវប៉ះពាល់ដល់សេរីភាពនៃអចលនទ្រព្យ វិជ្ជាជីវៈ និងការធ្វើដំណើរដោយសេរី) ។ ម្យ៉ាងវិញទៀត រាល់ការសម្រេចចិត្តទាំងអស់ដែលបញ្ជាក់អំពីការចំណាយធំដុំនៃថវិកាជាតិ មិនអាចទុកឱ្យនីតិប្រតិបត្តិធ្វើតែឯងបានទេ ប៉ុន្តែ វាទាមទារឱ្យមានការធ្វើការសម្រេចចិត្តបែបប្រជាធិបតេយ្យ ។

បញ្ជីត្រួតពិនិត្យខាងក្រោម អាចត្រូវបានប្រើសំរាប់ការពិនិត្យត្រួសៗ ប៉ុន្តែជាវិធីសាស្ត្រ **លើកទី១** លើអត្ថបទពង្រាងច្បាប់ (**ការចាត់ថ្នាក់ទី ១**):

| **ពង្រាងមាត្រាច្បាប់** | **តើមាត្រានេះមាន "ពាក្យមិនច្បាស់លាស់" ឬទេ?**<br><br>តើពាក្យមួយណា? | **តើមាត្រានេះប៉ះពាល់សិទ្ធិមនុស្សឬទេ?**<br><br>• សិទ្ធិណាមួយ?<br>• តើមានការដាក់កំហិតសិទ្ធិមនុស្សឬទេ?<br>• តើការដាក់កំហិតនេះធ្វើឡើងដើម្បីគោលបំណងអ្វី?<br>• តើការដាក់កំហិតនេះខ្លាំងពេកឬទេ? (រំលោភលើ "គោលការណ៍នៃភាពសមាមាត្រ" ឬទេ? | **តើមាត្រានេះកំណត់ប្រតិភូកម្មនៃអំណាចធ្វើបទបញ្ញត្តិឬទេ?**<br><br>តើអំណាចត្រូវបានធ្វើប្រតិភូកម្មច្រើនហួសហេតុឬទេ? (ការបំពានលើ "គោលការណ៍នៃការបែងចែកអំណាចឬទេ?) |
|---|---|---|---|
| មាត្រា១ | | | |
| មាត្រា២ | | | |
| មាត្រា៣ | | | |

ការប្រើបញ្ជីត្រួតពិនិត្យនេះ នឹងបង្ហាញកំហុសដែលមិនអាចលើកលែងឱ្យបាននៃពង្រាងច្បាប់ ។

## II) បញ្ជីត្រួតពិនិត្យពិស្តារ (ការចាត់ថ្នាក់ទី ២)

ដើម្បីឱ្យប្រាកដថា រកឱ្យឃើញនូវបញ្ហានៃការពង្រាងច្បាប់ ដែលកើតឡើងជាញឹកញាប់នោះ បញ្ជីត្រួតពិនិត្យពិស្តារខាងក្រោមនេះគួរតែត្រូវបានប្រើបន្ថែម ចំពោះអត្ថបទពង្រាងច្បាប់នៅក្នុងជំហានទី២ — **ការចាត់ថ្នាក់ទី ២** (សូមមើលក្រាហ្វិច: "បញ្ជីត្រួតពិនិត្យការធ្វើពង្រាងច្បាប់" ទំព័រទី ៧២) ។

| | មាត្រា | មាត្រា | មាត្រា |
|---|---|---|---|
| **ផ្នែកទី ១: គោលបំណង និង និយមន័យ** | ................ | ................ | ................ |
| • គោលបំណងនៃច្បាប់: អធម្មនុញ្ញភាព ឬទេ ? | ................ | ................ | ................ |
| • និយមន័យ: មិនច្បាស់លាស់ ឬខ្វះចន្លោះ ឬទេ? | ................ | ................ | ................ |
| • វិសាលភាពនៃច្បាប់ខ្លួនឯង: | ................ | ................ | ................ |
| តើករណីលើកលែងស្របនឹងសមភាពដែរឬទេ? | ................ | ................ | ................ |
| **ផ្នែកទី ២: សិទ្ធិ និងករណីយកិច្ច** | ................ | ................ | ................ |
| • ការពិពណ៌នានៃសិទ្ធិ: មានលក្ខណៈចង្អៀតឬ? | ................ | ................ | ................ |
| • ការការពារសិទ្ធិ: មិនគ្រប់គ្រាន់ ឬ ? | ................ | ................ | ................ |
| • គោលបំណងនៃការដាក់កំហិត: អធម្មនុញ្ញភាព? | ................ | ................ | ................ |
| • ការដាក់កំហិត: វិសមាមាត្រ? | ................ | ................ | ................ |
| - ការដាក់កំហិតទូទៅ | ................ | ................ | ................ |
| - ការដាក់កំហិតដោយមានការអនុញ្ញាតជាករណីលើកលែង | ................ | ................ | ................ |
| - ករណីយកិច្ចទទួលបាននូវការអនុញ្ញាត | ................ | ................ | ................ |
| - ករណីយកិច្ចជូនដំណឹងដល់អាជ្ញាធរមានសមត្ថកិច្ច | ................ | ................ | ................ |
| - ការអនុញ្ញាតពីអាជ្ញាធរមានសមត្ថកិច្ចធ្វើអន្តរាគមន៍ក្នុងករណី | ................ | ................ | ................ |
| មានការរំលោភសិទ្ធិ | ................ | ................ | ................ |
| **ផ្នែកទី ៣: ភ្នាក់ងារប្រតិបត្តិ និង ដំណើរការរដ្ឋបាល** | ................ | ................ | ................ |
| • សមត្ថកិច្ច: មិនច្បាស់លាស់ ឬ ត្រួតគ្នា? | ................ | ................ | ................ |
| • ការផ្តល់អំណាចជ្រុលហួសហេតុ ឬ?" | ................ | ................ | ................ |
| - អធម្មនុញ្ញភាព ឬ អំណាចមិនចាំបាច់ | ................ | ................ | ................ |
| - អំណាចតុលាការ ឬ មិនរាប់បញ្ចូលការត្រួតពិនិត្យអង្គយុត្តាធិការ ? | ................ | ................ | ................ |
| - ប្រតិភូកម្មអំណាចបង្កើតច្បាប់ជ្រុលហួសហេតុ? | ................ | ................ | ................ |
| **ផ្នែកទី ៤: អវសានប្បញ្ញត្តិ** | ................ | ................ | ................ |
| • ទោសប្បញ្ញត្តិ: អធម្មនុញ្ញភាព , វិសមាមាត្រ? | ................ | ................ | ................ |
| • ក្របខ័ណ្ឌពេលវេលា ឬអន្តរប្បញ្ញត្តិ: ខ្វះខាត ? | ................ | ................ | ................ |
| • ប្រការដែលចែងអំពីនរាករណ៍: មិនច្បាស់លាស់ ? | ................ | ................ | ................ |
| **តំរូវការទូទៅគ្រប់ផ្នែកនៃច្បាប់** | ................ | ................ | ................ |
| • ភាសា: មិនអាចយល់បាន ឬ ? | ................ | ................ | ................ |
| • ពាក្យ: មិនសមស្រប ឬ មានបញ្ហា ឬ? | ................ | ................ | ................ |
| • ការរៀបចំ ជំពូក និងផ្នែក នៃច្បាប់: សមស្របដែរឬទេ ? | ................ | ................ | ................ |
| • សមស្របទៅនឹងច្បាប់ខ្លួនឯងដែរឬទេ ? | ................ | ................ | ................ |
| • ស្របទៅនឹងច្បាប់ផ្សេងៗ: ផ្ទុយទៅនឹងច្បាប់ផ្សេងៗដែរឬទេ ? | ................ | ................ | ................ |

ការពិនិត្យអត្ថបទពង្រាងច្បាប់ត្រួសៗ និង បន្ថែមតាមលក្ខណៈពិស្ដារដូចពោលខាងលើ នឹងផ្ដល់ការបញ្ចេញយោបល់ច្រើនទៅលើមាត្រានីមួយៗនៃពង្រាងច្បាប់ ។

## គ) សេចក្ដីសន្និដ្ឋានចុងក្រោយ និងសំណើសំរាប់វិសោធនកម្ម:

នៅក្នុងករណីជាច្រើន ដើម្បីធ្វើវិភាគទានដ៏មានតម្លៃចំពោះដំណើរការធ្វើពង្រាងច្បាប់នោះ ការគូសបញ្ជាក់នូវចំណុចខ្វះខាតនៃមាត្រាពង្រាងច្បាប់តែម្យ៉ាងប៉ុណ្ណោះ នោះមិនទាន់គ្រប់គ្រាន់ទេ ។

ដើម្បីធ្វើឱ្យមិត្តអ្នកអានងាយយល់ថា តើផ្នែកណាមួយនៃអត្ថបទពង្រាងច្បាប់ត្រូវកែប្រែ និងថាតើពង្រាងនេះ ត្រូវកែប្រែតាមវិធីណានោះ យើងសុំផ្ដល់អនុសាសន៍ឱ្យប្រើប្រាស់ឱយ៉ាក្រោមដូចខាងក្រោម:

| | |
|---|---|
| នៅក្នុងក្រឡោន**ខាងឆ្វេង** អត្ថបទនៃពង្រាងច្បាប់ត្រូវបំពេញម្ដងមួយមាត្រាៗ :<br>• ផ្នែកទាំងឡាយនៃអត្ថបទនេះដែលត្រូវ**លុបចោល** តាមសំណើត្រូវ**~~គូសបន្ទាត់ឆូតចោល~~** ដើម្បីឱ្យអ្នកអាននៅតែឃើញច្បាស់នូវពាក្យណាដែលមិនត្រូវប្រើតទៅទៀត ។<br>• ផ្នែកនៃអត្ថបទ និងពាក្យទោលទាំងឡាយណាដែលត្រូវបញ្ចូល**បន្ថែម**ទៅក្នុងអត្ថបទពង្រាងច្បាប់ ត្រូវបញ្ជាក់ឱ្យបានច្បាស់ដោយ**<u>ការគូសបន្ទាត់ពីក្រោម</u>** ។<br>• ផ្នែកនៃអត្ថបទដែល**លើកឡើងនូវមន្ទិលសង្ស័យ** អាចគូសចំណាំដោយ ***អក្សរទ្រេត*** ។ | នៅក្នុងក្រឡោន **ខាងស្ដាំ** ត្រូវបញ្ចូលយោបល់ និងហេតុផលសំរាប់ការធ្វើសំណើរកែប្រែ ។<br>គេអាចប្រមូលទស្សនៈរបស់អ្នកបញ្ចេញយោបល់ផ្សេងៗនៅក្នុងក្រឡោនខាងស្ដាំនេះ ក៏ប៉ុន្តែគួរតែបញ្ជាក់ឱ្យច្បាស់ថាតើយោបល់នោះ ចេញមកពីប្រភពណា? |

| អត្ថបទកែប្រែនៃមាត្រាពង្រាងច្បាប់<br>(ប៉ុន្តែនៅតែបង្ហាញអត្ថបទដើមនៅពេលជាមួយគ្នា) | យោបល់ និងហេតុផលសំរាប់ការធ្វើសំណើកែប្រែ |
|---|---|
| **មាត្រា១** | |
| **មាត្រា២** | |
| **ឧទាហរណ៍ មាត្រា៣១ នៃច្បាប់ជលផល**<br><br>ក. ត្រូវហាមឃាត់ការចាប់ ការដាក់អន្ទាក់ ការធ្វើឱ្យរបួស ការសម្លាប់ ការដឹកជញ្ជូន ការលក់ ការទិញ ការកែច្នៃ និង**~~ការធ្វើសន្និធិ~~** **<u>ការកាន់កាប់</u>** នូវសត្វស្លាបទឹកគ្រប់ប្រភេទ **<u>និងពងរបស់វា</u>** ។<br><br>ខ. គ្រប់សកម្មភាពខាងលើនេះ អាចប្រព្រឹត្តិទៅបានលុះត្រាតែមាន ***ការអនុញ្ញាត*** ពិសេស ។<br><br>គ. ប្រភេទ ***សត្វស្លាបទឹក*** គ្រប់ប្រភេទ ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ។ | ក. កែ"ការធ្វើសន្និធិ"ទៅជា "ការកាន់កាប់នូវ" ។ បន្ថែម "និងពងរបស់វា" [MRC]<br><br>ខ. មាត្រានេះមានលក្ខណៈមិនច្បាស់លាស់ ។ គេត្រូវតែកំណត់និយមន័យនៃពាក្យ "ការអនុញ្ញាតពិសេស": តើអ្នកណាអាចផ្ដល់ការអនុញ្ញាតនេះ ក្រោមលក្ខខណ្ឌបែបណាខ្លះ អាស្រ័យលើគោល-ការណ៍ណែនាំអ្វីខ្លះ ។ល។ តើការអនុញ្ញាតនេះសំរាប់ការស្រាវជ្រាវ ឬក៏សកម្មភាពផ្សេងទៀតដែរឬទេ? តើវាជាការអនុញ្ញាតនៅក្រោមសេចក្ដីព្រាងមាត្រា៧១.១៣ ឬទេ?<br>[COUNHCHR, សិក្ខាសាលាតំបន់ទន្លេមេគង្គ, Swift]<br><br>គ. គេត្រូវពិនិត្យមើលឡើងវិញលើមាត្រានេះ ដើម្បីធានាឱ្យបានថា វាមិនប្រឆាំងគ្នាជាមួយនឹងច្បាប់បរិស្ថានជាធរមាន។ ជំពូកទី១០ នៃច្បាប់ព្រៃឈើ(អភិរក្សសត្វព្រៃ) ដាក់"សត្វស្លាប"ទាំងអស់ នៅក្រោមការគ្រប់គ្រងរបស់រដ្ឋបាលព្រៃឈើ ប៉ុន្តែមាត្រានេះ ដាក់ "សត្វស្លាបទឹក"ទាំងអស់ នៅក្រោមអំណាចរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ដែលក្នុងនោះមានរដ្ឋបាលព្រៃឈើជានាយកដ្ឋានមួយ)[COUNHCHR] |

## ? សំនួរសិក្សាទី ២០

សូមរៀបរាប់ បណ្ដាសិទ្ធិមនុស្សទាំងឡាយដែលអ្នកបានរកឃើញនៅក្នុងរដ្ឋធម្មនុញ្ញកម្ពុជា ព្រមទាំងបញ្ជាក់ឈ្មោះ និងដកស្រង់នូវមាត្រាដែលពាក់ព័ន្ធផង ។

ព្រមទាំងបញ្ជាក់ឈ្មោះនៃការដាក់កំហិតទៅលើសិទ្ធិទាំងនោះ!

## ? សំនួរសិក្សាទី ២១

សូមបើកនូវ web-page: www.online.com.kh/users/kid ដូចខាងក្រោមៈ

→ បន្ទាប់មកចូល "**Related Links**",

→ រួចហើយ "**Legal Education**",

→ និងបន្ទាប់មកទៀតចូល

"**Human Rights Network International (HRNi Bruxelles)**" ។

សូមរក "សេចក្ដីប្រកាសអង្គការសហប្រជាជាតិស្ដីពីការកំចាត់ចោលរាល់នូវទំរង់នៃការមិនអនុគ្រោះ និងការរើសអើង ខាងវិស័យជំនឿ ឬសាសនា" ។

សូមដកស្រង់នូវមាត្រាពាក់ព័ន្ធដែលបញ្ញត្តិអំពីការកំហិតទៅលើសេរីភាពខាងសាសនា និងបញ្ជាក់ពីបណ្ដាហេតុផលនានានៃការដាក់កំហិតនោះផង ។

# ? សំនួរសិក្សាទី ២២

ចូរបំពេញតារាងខាងក្រោម និងអនុវត្តជំនាញរបស់អ្នកក្នុងការផ្តល់មតិយោបល់លើច្បាប់!

| **មាត្រានៃពង្រាងច្បាប់ ស្តីពីការគ្រប់គ្រងអាវុធជាតិផ្ទុះ** | **ការផ្តល់យោបល់វិភាគលើ មាត្រានៃពង្រាងច្បាប់** (ចូរបំពេញយោបល់វិភាគ របស់អ្នកនៅទីនេះ) | **សំណើមាត្រាដែលត្រូវធ្វើ វិសោធនកម្ម** (ចូរបំពេញសំណើវិសោធនកម្ម របស់អ្នកនៅទីនេះ) |
|---|---|---|
| មាត្រា១១ កថាខ័ណ្ឌទី ១:<br>"ក្រសួងការពារជាតិ មានសមត្ថកិច្ចចេញប័ណ្ណសំគាល់ សិទ្ធិប្រើប្រាស់អាវុធ គ្រឿងផ្ទុះ និងគ្រាប់រំសេវគ្រប់ប្រភេទ ដល់កងយោធពលខេមរភូមិន្ទ។" | ...................................<br>...................................<br>...................................<br>................................... | ...................................<br>...................................<br>...................................<br>................................... |
| មាត្រា១២ កថាខ័ណ្ឌទី ៣:<br>"អាវុធទាំងអស់ ត្រូវចុះក្នុងបញ្ជី ហើយអាវុធគ្រប់ប្រភេទ ត្រូវតែស្តុកទុក និងបញ្ចូលក្នុងឃ្លាំងដែលមានសុវត្ថិភាព ។ ការលើកលែងករណីនេះ អាចធ្វើទៅបានតាមរយៈប្រកាសអន្តរក្រសួងការពារជាតិ និងក្រសួងមហាផ្ទៃ ។" | ...................................<br>...................................<br>...................................<br>...................................<br>...................................<br>................................... | ...................................<br>...................................<br>...................................<br>...................................<br>...................................<br>................................... |
| មាត្រា២០:<br>"ត្រូវផ្តន្ទាទោសដាក់ពន្ធនាគារពី ៥ឆ្នាំ ដល់ ១០ឆ្នាំ ដោយពុំទាន់គិតពីបទល្មើសព្រហ្មទណ្ឌផ្សេងទៀត ចំពោះជនណាដែលបានប្រព្រឹត្តផ្ទុយនឹងមាត្រា៨ និង ១៤ នៃ ច្បាប់នេះ ។" | ...................................<br>...................................<br>...................................<br>...................................<br>................................... | ...................................<br>...................................<br>...................................<br>...................................<br>................................... |